ព្រះរាជាណាចក្រកម្ពុជា

Inform-សជណ/ 21-02-18/រ៉-បល-P.188

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ១៣៣៦ អជណ · អក·ធម

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក **ប្រចាំការអនុស្ថានីយ (អនុស្ថានីយតេនមណ្ឌល ខេត្តបាត់ដំបង** ចំនួន ០៤ រូប, **អនុស្ថានីយស្ទឹងត្រែង** ចំនួន ០៤ រូប, **អនុស្ថានីយតំបន់សេដ្ឋកិច្ចពិសេស កំបូល** ចំនួន ០៧ រូប, **អនុស្ថានីយទី១** ចំនួន ០១ រូប, **អនុស្ថានីយទី៣** ចំនួន ០១ រូប, **អនុស្ថានីយទី៤** ចំនួន ០២ រូប, **អនុស្ថានីយឈូក** ចំនួន ០១ រូប, **អនុស្ថានីយបន្ទាយមាស** ចំនួន ០១ រូប, **អនុស្ថានីយកំពត** ចំនួន ០១ រូប, **អនុស្ថានីយកំពង់សីល្ហ** ចំនួន ០១ រូប, **អនុស្ថានីយប្រេកម្នេស** ចំនួន ០៣ រូប, **អនុស្ថានីយកំពង់ស្ពឺ** ចំនួន ០២ រូប, **អនុស្ថានីយតាកែ** ចំនួន ០២ រូប និង **អនុស្ថានីយអូរសោម** ចំនួន ០១ រូប) សរុបចំនួន ៣៩ រូប ដើម្បីចូលបម្រើការងារនៅអង្គភាពបណ្តាញបញ្ជូន នៃនាយកដ្ឋានបញ្ជូនអគ្គិសនី ដូចខាងក្រោម :

*- **<u>លក្ខណៈសម្បត្តិបេក្ខជន</u>** :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

*- **<u>បញ្ជាក់</u>** : ប្រសិនបើលទ្ធផលពិន្ទុ ប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាពជូន :

- ជនពិការ
- បេក្ខជន មានអាសយដ្ឋានស្ថិតនៅខេត្តសាមី ។

***- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា បេក្ខជនត្រូវទាញយក (Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ :www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើ ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា ។**

*- **<u>បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ</u>** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |

***- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ I នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨

*- **<u>ទីកន្លែងទទួលពាក្យ</u>** : នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃផ្សាយដំណឹងនេះ ហូតដល់ថ្ងៃទី២៧ខែមីនា ឆ្នាំ២០១៨ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **<u>ព័ត៌មានផ្សេងៗ</u>** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ អង្គារ ០៥ រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៨

**ជ. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

ELECTRICITE DU CAMBODGE

កែវ_រតនា

**<u>បញ្ជាក់</u>**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ "។